# មេរៀនទី ៣៥៖ ឡុត និងអាប់រ៉ាមបែងចែកទឹកដីគ្នា

## លោកុប្បត្តិ ១៣

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/W-CK8g-AfqA

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/aQKgkcM-x9A

**គោលបំណង៖ ព្រះនាំមកនូវសន្តិភាព។**

**ខគម្ពីរចងចាំ៖ យ៉ូហាន ១៤៖២៧** *"ខ្ញុំទុកសេចក្ដីសុខនៅនឹងអ្នករាល់គ្នា គឺខ្ញុំឲ្យសេចក្ដីសុខសាន្ត របស់ខ្ញុំដល់អ្នករាល់គ្នា ហើយដែលខ្ញុំឲ្យ នោះមិនមែនដូចជាលោកីយ៍ឲ្យទេ កុំឲ្យចិត្តអ្នករាល់គ្នា ថប់បារម្ភ ឬភ័យឡើយ ។"*

**ចំរៀង** ( *យូធូបលីង* )៖

១. ខ្ញុំទុកចិត្តលើព្រះយេស៊ូវ https://youtu.be/Vq_yln2huAM

២. ស្ដេចលើស្ដេច https://youtu.be/CPBqHYVwm3M

៣. ក្ដីសុខសាន្ត https://youtu.be/N9mBBb9zljw

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត** «ប្រណាំងគ្នាផឹកកូកា»




សម្ភារៈដែលត្រូវការ៖ កែវក្រដាស កូកា ទុយោ តុ ក្រមា

១. ចែកកុមារ៥ក្រុម ហើយរើសតំណាងក្រុមម្នាក់មួយក្រុមមក

២. បិតភ្នែកកុមារហើយនាំគេទៅកាន់តុ ហើយឲ្យទុយោទៅពួកគេ។ នៅលើតុ គ្រូត្រូវចាក់កូកាទៅក្នុងកែវ ទាំង៥

៣. កុមារត្រូវស្វែងរកកូការបស់ពួកគេ ដោយបិតភ្នែកនិងផឹកវា។ កុមារណាដែលអាចស្វែងរកកូកានិង ផឹកវាបានមុនគេនោះក្រុមគេនឹងទទួលបានមួយពិន្ទុ។ ប្រសិនបើគេធ្វើឲ្យកូកាខ្ទាយនោះគេនឹងចាញ់ល្បែងនេះ

៤. បន្តលេងល្បែងនេះរហូតដល់កុមានបានលេងគ្រប់ៗគ្នា។ ក្រុមណាដែលទទួលបានពិន្ទុច្រើនជាគេក្រុមគេជាអ្នកឈ្នះ។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ប្រសិនបើយើងដាក់ទុយោចូលក្នុងកែវរបស់ក្រុមផ្សេងនោះគេនឹងខឹងអ្នក។ នោះគេនឹងមិនមានសន្តិភាពនៅក្នុងចិត្តទេ។ ប៉ុន្តែព្រះគឺតែងតែចង់ផ្ដល់នូវសន្តិភាពដល់យើងជានិច្ច។

**៤. ការណែនាំមេរៀន**

យើងអាចនិយាយថាអ្នកកពុងតែនៅផ្ទះជាមួយជីតារបស់អ្នក។ មាននរណាម្នាក់ឲ្យនំ២ទៅអ្នក តែនំ១ធំ ហើយនំមួយទៀតតូច។ តើអ្នកនឹងឲ្យនំមួយណាទៅលោកតារបស់អ្នក? នំធំ ឬនំតូច? ជាធម្មតាតើយើងនឹងឲ្យនំធំជាងគេជូនទៅមនុស្សចាស់ដូចជាជីតារបស់អ្នក? ថ្ងៃនេះយើងនឹងរៀនពីលោកពូម្នាក់ដែលបានឲ្យភាពត្រឹមត្រូវរបស់គាត់ទៅក្មួយប្រុសរបស់គាត់ពីព្រោះគាត់ចង់រក្សាសន្តិភាព។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

បន្ទាប់ពីអាប់រ៉ាមបានចាកចេញពីស្រុកកំណើតខារ៉ានជាមួយប្រពន្ធ និងក្មួយប្រុសរបស់គាត់ឡុត។ ព្រះបានដឹកនាំពួកគេទៅទឹកដីថ្មី។ អាប់រ៉ាម និងក្មួយប្រុសរបស់គាត់ឡុតបានរស់នៅក្បែរគ្នា។ ពួកគេជាអ្នកគង្វាលសត្វ គឺមានន័យថាពួកគេជាអ្នកមើលថែសត្វជាច្រើន។ ពួកគេមានហ្វូងសត្វ និងហ្វូងចៀមជាច្រើន បូករួមទាំងអ្នកបំរើដែលជាអ្នកជួយពួកគេមើលថែសត្វទាំងអស់នោះ។

តំបន់ដែលអាប់រ៉ាម និងឡុតរស់នៅគឺមានមនុស្សច្រើន។ មានសត្វ និងអ្នកបំរើច្រើនណាស់ ហើយអត់មាន បន្ទប់គ្រប់សំរាប់ពួកគេស្នាក់នៅទេ។ អត់មានស្មៅគ្រប់គ្រាន់សំរាប់សត្វស៊ីទេ ហើយក៏អត់មានទឹកគ្រប់ គ្រាន់សំរាប់ពួកគេទាំងអស់ផឹកដែរ។ មិនយូរប៉ុន្មានអ្នកបំរើរបស់អាប់រ៉ាមក៏ចាប់ផ្តើមប្រកែកគ្នា។

តាមពិត អ្នកបំរើរបស់អាប់រ៉ាម និងអ្នកបំរើរបស់ឡុតចាប់ផ្តើមឈ្លោះប្រកែកគ្នា។ អ្នកបំរើរបស់អាប់រ៉ាមចង់ឲ្យសត្វ របស់ខ្លួនមានចំណីស៊ី និងទឹកផឹកគ្រប់គ្រាន់។ ហើយអ្នកបំរើរបស់ឡុតចង់ឲ្យសត្វខ្លួនមានចំណីស៊ី និងទឹកផឹកគ្រប់គ្រាន់ដែរ។ រឿងនេះវាមិនមែនសន្តិភាពណាស់ណាទេ។

អាប់រ៉ាមក៏សំរេចចិត្តថា វាមិនមែនជារឿងល្អទេដែលអ្នកបំរើចាប់ផ្តើមឈ្លោះប្រកែកគ្នា។ គាត់បាននិយាយជាមួយឡុតថា "សូមកុំឲ្យយើងមានជម្លោះរវាងគ្នានិងគ្នា ឬរវាងអ្នកបំរើរបស់យើងទាំងសងខាង។ បើយើងបែងចែកគ្នា គឺនៅទីនេះយើងមានដី អាហារ និងទឹកគ្រប់គ្រាន់សំរាប់យើងទាំងអស់គ្នា។ អ្នកអាចសម្រេចចិត្តតើយើងនឹងធ្វើអ្វីខ្លះ។ បើសិនអ្នកចង់ទៅខាងកើត ខ្ញុំនឹងរើសយកដីខាងលិច។ បើសិនអ្នកចង់រើសយកខាងលិច ខ្ញុំនឹងរើសយកខាងកើត។"

ឡុតគាត់ពេញចិត្តនឹងគំនិតនេះពីព្រោះគាត់រើសបានដីដែលល្អជាង។ អាប់រ៉ាមអាចនឹងគិតថាពីព្រោះគាត់ចាស់ជាងគាត់អាចរើសបានដីល្អជាង ហើយឲ្យដីមិនល្អទៅឡុត។ ប៉ុន្តែអាប់រ៉ាមមានក្តីស្រឡាញ់របស់ព្រះ ព្រះនាំមកនូវសន្តិភាព។ ដូច្នេះឡុតបានសម្លឹងមើល ហើយក៏រើសទឹកដីទន្លេយ័រដាន់ និងទឹកដីទិសខាងកើត ជារបស់ខ្លួនពីព្រោះវាមើលទៅដូចជាទឹកដីល្អជាងគេ។ ហើយអាប់រ៉ាមក៏ព្រមរស់នៅលើទឹកដីកាណាន ដោយគ្មានត្អូញត្អែរមួយម៉ាត់។

បន្ទាប់ពីការឈ្លោះប្រកែកគ្នាត្រូវបានដោះស្រាយ ហើយឡុត និងអាប់រ៉ាមក៏បានចែកផ្លូវគ្នា ព្រះបានប្រទានពរទឹកដីដែលនៅជុំវិញទីនោះដល់អាប់រ៉ាម។ ព្រះបានប្រាប់អាប់រ៉ាមថា ក្រុមគ្រួសាររបស់គាត់នឹងរីកចម្រើន ហើយរីកចម្រើនថែមទៀត។ អាប់រ៉ាម និងគ្រួសាររបស់គាត់បានរីកចម្រើនរុងរឿងនៅទីនោះ ហើយបានរស់នៅទីនោះរហូតមក។ ជាចុងក្រោយ អាប់រ៉ាមបានស្វែងរកឃើញទឹកដីដែលព្រះបានសន្យាជាមួយគាត់ជាទឹកដីសន្យារបស់ព្រះ។ ដូច្នេះអាប់រ៉ាមបានតាំងត្រសាលនៅទីនោះ នៅក្បែរហេប្រុន ហើយគាត់បានសាងអសានា១ថ្វាយដល់ព្រះជាម្ចាស់នៅទីនោះ។

នៅពេលដែលយើងបានប្រព្រឹត្តជាមួយនរណាម្នាក់ដោយក្តីសប្បុរស និងក្តីស្រឡាញ់ យើងក៏ចង់ទទួលបានការប្រព្រឹត្តបែបនោះវិញដែរ ជីវិតរបស់យើងនឹងពោរពេញដោយសន្តិភាព។ ព្រះនាំមកនូវសន្តិភាព ដូច្នេះសូមឲ្យយើងធ្វើតាមផ្លូវរបស់ព្រះដូចអាប់រ៉ាមបានធ្វើ!

## ៦. សំនួរពិភាក្សា

១.តើអាប់រ៉ាម និង ឡុតមានបញ្ហាអ្វី?

*(អ្នកបំរើរបស់ពួកគេឈ្លោះប្រកែកគ្នាពីព្រោះពួកគេទាំងពីរនាក់មានសត្វច្រើនណាស់រស់នៅក្បែរគ្នា)*

២.ហេតុអ្វីបានជាអាប់រ៉ាមឲ្យក្មួយប្រុសរបស់គាត់ឡុតរើសទឹកដីដែលល្អជាង?

*(ពីព្រោះអាប់រ៉ាម ចង់មានសន្តិភាពជាមួយឡុត)*

៣.តើព្រះបានសន្យាអ្វីជាមួយអាប់រ៉ាមបន្ទាប់ពីឡុតបានចាកចេញពីគាត់?
*(ព្រះបានសន្យាថានឹងឲ្យ ទឹកដីកាណានទៅអាប់រ៉ាម និងកូនចៅជំនាន់ក្រោយរបស់គាត់ជារាងរហូត)*
៤.តើអ្វីធ្វើឲ្យអ្នកអាចរក្សាសន្តិភាពបានជាមួយអ្នកដទៃ? *(សូមឲ្យកុមារឆ្លើយ)*

## ៧. ល្បែងកំសាន្ត «ឆ្លើយសំនួរយករង្វាន់»

សម្ភារៈដែលត្រូវការ៖ កាដូរចំនួន១០ (តែកាដូរ៥ មានរង្វាន់ ហើយ៥ទៀតមិនមានរង្វាន់នោះទេ)
(ជាជម្រើស៖ ប្រសិនបើគ្មានកាដូរអាចប្រើកែវក្រដាសក៏បាន)



១. គ្រូត្រូវត្រៀមសំណួរចំនួន១០ (អាចប្រើសំណួរទាំង៤នៅក្នុងមេរៀននេះ ក៏បាន)
២. ចែកកុមារជា២ ក្រុមហើយឲ្យពួកគេអង្គុយជាជួរ
៣. ក្រុមនីមួយនឹងបញ្ជូនតំណាងក្រុមម្នាក់មកប៉ាវ។ ក្រុមដែលឈ្នះនឹងរើសសំណួរមួយ ពីសំណួរទាំង ១០ ។ ប្រសិនបើគេឆ្លើយត្រូវនោះគេអាចរើសកាដូរបាន១។ ប្រសិនបើគេឆ្លើយខុសនោះ ក្រុមមួយទៀតអាចឆ្លើយសំណួរនោះបាន។ ក្រុមណាដែលអាចឆ្លើយសំណួរត្រូវអាចជ្រើសកាដូរនោះបាន។ ពួកគេអា ច រើសបានកាដូរដែលមានរង្វាន់ឬប៉ះចំកាដូរដែលគ្មានរង្វាន់។
៤. បន្តលេងល្បែងនេះរហូតដល់សំណួរទាំង១០បានសួរអស់។
៥. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា បើទោះបីជាកាដូរទាំងអស់មើលទៅស្អាតក៏ដោយ ក៏មិនប្រាកដថា គេទទួលបានកាដូរល្អនោះដែរ។ ឡុតបានគិតថាគាត់បានជ្រើសរើសទឹកដីដ៏ល្អ ប៉ុន្តែ អាប់រាមទទួលបានទឹកដីល្អជាងទៅវិញ ពីព្រោះគាត់បានជ្រើសរើសសន្តិភាពដែលមកពីព្រះ។

## ៨. ខគម្ពីរចងចាំ

**យូហ៉ាន ១៤៖២៧** *"ខ្ញុំទុកសេចក្តីសុខនៅនឹងអ្នករាល់គ្នា គឺខ្ញុំឲ្យសេចក្តីសុខសាន្ត របស់ខ្ញុំដល់អ្នករាល់គ្នា ហើយដែលខ្ញុំឲ្យ នោះមិនមែនដូចជាលោកីយ៍ឲ្យទេ កុំឲ្យចិត្តអ្នករាល់គ្នា ថប់បារម្ភ ឬភ័យឡើយ ។"*

## ៩. ហាត្ថកម្ម "ឡុត និងអាប់រ៉ាមបែកចែកទឹកដីគ្នា"

សម្ភារៈដែលត្រូវការ៖ បោះពុម្ពក្រដាសហាត្ថកម្ម កូល័រផាត់ព៌ណ កន្ត្រៃ និង កាវបិត
១. ចែកក្រដាសហាត្ថកម្មឲ្យកុមារម្នាក់១សន្លឹក ហើយឲ្យកុមារផាត់ព៌ណក្រដាសហាត្ថកម្មនោះ។
២. កាត់រូបអាប់រ៉ាម និង រូបឡុតចេញមក ហើយយករូបទាំងពីរនោះមកនៅជ្រុងដែលត្រឹមត្រូវ។ គួរតែបិតរូបអាប់រ៉ាមនៅខាងក្រោមទឹកដីកាណាន ហើយ គួរតែបិតរូបឡុតនៅខាងក្រោមទឹកដីទន្លេយ័រដាន់
៣. ពន្យល់ដល់កុមារថា ដើម្បីរក្សាសន្តិភាពក្នុងគ្រួសារ អាប់រ៉ាម អនុញ្ញាតិឲ្យឡុតជ្រើសរើសមុន។ ផ្លូវរបស់ព្រះតែងតែនាំមកនូវសន្តិភាព។

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ព្រះបន្ទូលរបស់ព្រះយេស៊ូវជាចិត្តដែលមិនអាត្មានិយម និងចិត្តដែលបំរើ គឺជាចំណុចកណ្តាល ដើម្បីធ្វើឲ្យទំនាក់ទំនងរបស់យើងជាមួយអ្នកដទៃបានប្រសើឡើង។ សូមពិចារណាអំពីទំនាក់ទំនង ដែលមានសារៈសំខាន់ចំពោះអ្នក។ តើទំនាក់ទំនងនោះកាន់តែប្រសើរឡើងយ៉ាងដូចម្តេចបើសិនជាអ្នក ទុកអ្នកដទៃមុន? សូមសម្លឹងរកមើលឱកាសនៅក្នុងសប្តាហ៍ថ្មីៗដើម្បីទុកអ្នកដទៃមុន ហើយរងចាំមើល ថាវាមានអ្វីផ្លាស់ប្តូរខ្លះ។ សូមប្តេជ្ញាចិត្តដើម្បីអធិស្ឋានសំរាប់អ្នកដទៃ និងសូមជំនួយមកពីព្រះដើម្បីរក្សា ចិត្តរបស់អ្នក នៅក្នុងស្ថានភាពដ៏ត្រឹមត្រូវ គឺដាក់ខ្លួន និងមានក្តីស្រឡាញ់។

# ឡុត និង អាប់រ៉ាមបែកចែកទឹកដីគ្នា

កាណាន យ័រដាន់



អាប់រ៉ាម



ឡុត

